**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លក្ខន្តិកៈ

# សមាគមន៍អ្នកគណិតវិទ្យាកម្ពុជា

# STATUTE OF

# CAMBODIAN MATHEMATICAL SOCIETY

## ជំពូកទី ១

## ការបង្កើតសមាគមន៍

**មាត្រា ១** : សមាគមន៍មួយត្រូវបានបង្កើតឡើង ដោយបញ្ញវ័ន្តខ្មែរ ថ្នាក់បណ្ឌិត អនុបណ្ឌិត បរិញ្ញាប័ត្រ លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាស្រាវជ្រាវគ្រប់កម្រិតដែលមានឯកទេសគណិតវិទ្យា។ សមាគមន៍នេះ មានឈ្មោះថា "**សមាគមន៍អ្នកគណិតវិទ្យាកម្ពុជា**" ដោយប្រើអក្សរកាត់ថា "**សអគក**" និងមានឈ្មោះជាភាសាអង់គ្លេសថា **"Cambodian Mathematical Society"** ដោយប្រើអក្សរកាត់ថា **"CMS"** ដែលជាអង្គការក្រៅរដ្ឋាភិបាល អព្យាក្រឹត មិនស្វែងរកប្រាក់ចំណេញជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍នយោបាយ ក្នុងនោះរួមទាំងមិនផ្តល់មធ្យោបាយជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយ ហើយសមាគមន៍នេះគ្មានបេរវលាក់លាក់ឡើយ។

**មាត្រា ២** : សអគក មានរូបសញ្ញា និងត្រាដោយឡែករបស់ខ្លួន ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

**មាត្រា ៣** : សអគក មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ ហើយអាចមានសាខានៅតាមគ្រឹះស្ថានសិក្សានានា ក្នុងខេត្ត-ក្រុង ទូទាំងប្រទេស តាមការចាំបាច់។

## ជំពូកទី ២

## គោលបំណង និងទិសដៅ

**មាត្រា ៤** : សអគក មានគោលបំណងលើកស្ទួយការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ លើផ្នែកគណិតវិទ្យា ទាំងក្នុង និងក្រៅប្រទេស សម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់សង្គមជាតិ មនុស្សជាតិ និងពិភពលោកទាំងមូល។ សអគក មានទិសដៅលើកគម្រោងស្រាវជ្រាវលើផ្នែកវិទ្យាសាស្ត្រគណិតវិទ្យា និងអនុវត្តន៍ រៀបចំវេទិកាវិទ្យាសាស្ត្រ ធ្វើសិក្ខាសាលា ប្រមូលចងក្រងឯកសារ និងផ្សព្វផ្សាយឯកសារស្រាវជ្រាវអំពីវិទ្យាសាស្ត្រគណិតវិទ្យានៅប្រទេសកម្ពុជា និងបណ្តាប្រទេសនៅក្នុងតំបន់ក៏ដូចជានៅលើពិភពលោក លើកទឹកចិត្ត

និងបោះពុម្ពផ្សាយស្នាដៃ ស្រាវជ្រាវវិទ្យាសាស្ត្រគណិតវិទ្យា ព្រមទាំងធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអង្គការ សមាគមជាតិ និងអន្តរជាតិដែលមានគោលបំណងដូចគ្នា និងពង្រីកទំនាក់ទំនងឱ្យមានភាពស្និទ្ធស្នាលរវាងបញ្ញវ័ន្តខ្មែរ និងបរទេស ។

**មាត្រា ៥** : មូលដ្ឋានចាំបាច់នៃដំណើរការរបស់ សអគក ពឹងផ្អែកលើគោលការណ៍ធំៗពីរ ÷

១- ម្ចាស់ការលើខ្លួនឯង ។

២- ស្វែងរកជំនួយពីអង្គការ សមាគមនានា ក្នុង និងក្រៅប្រទេស ព្រមទាំងរាជរដ្ឋាភិបាល និងសប្បុរសជននានា ដោយមិនគិតនិន្នាការនយោបាយឡើយ ។

## ជំពូកទី ៣

## សមាជិក និងការបាត់បង់សមាជិកភាព

**មាត្រា ៦** : និស្សិត បញ្ញវ័ន្ត អ្នកស្រាវជ្រាវដែលមានឯកទេសគណិតវិទ្យា ទាំងខ្មែរ និងបរទេស និងបុគ្គលដទៃទៀត អាចសុំចូលជាសមាជិកស្រាវជ្រាវ ឬសមាជិកគាំទ្រ សអគក បាន ដោយមិនប្រកាន់ភេទ ពណ៌សម្បុរ សាសនា និងនិន្នាការនយោបាយឡើយ ។

**មាត្រា ៧** : សមាជិករបស់ សអគក ចែកចេញជាពីរប្រភេទគឺ ÷

១. សមាជិកស្រាវជ្រាវ :

ក- សមាជិកស្ថាបនិក គឺជាអ្នកដែលផ្តួចផ្តើមបង្កើត សអគក ដោយផ្ទាល់ ។

ខ- សមាជិកសកម្ម គឺជាសមាជិកដែលមានឆន្ទៈក្នុងការស្រាវជ្រាវបម្រើឱ្យ សអគក ។

២. សមាជិកគាំទ្រ :

ក- សមាជិកកិត្តិយស ជាសមាជិក ដែលជួយឧបត្ថម្ភ សអគក ខាងផ្លូវចិត្ត ផ្តល់គំនិត និងធ្វើអំណោយក្នុងតម្លៃ ១.៥០០.០០០៛ ( មួយលានប្រាំសែនរៀល ) ឡើងដល់សហគមន៍ ដោយឥតទាមទារផលប្រយោជន៍ពីសហគមន៍វិញឡើយ ។

ខ- សមាជិកគាំទ្រ គឺជាសមាជិកដែលមានចិត្តសោមនស្សចំពោះគោលបំណង និងកម្មវិធី សកម្មភាពរបស់ សអគក អាចជួយសហគមន៍ តាមសេចក្តីជ្រះថ្លារបស់ខ្លួន ទាំងកម្លាំងកាយ-ចិត្ត ព្រមទាំងថវិកា និងសម្ភារៈផ្សេងៗ មិនកំណត់ចំនួន តាមលទ្ធភាព និងពេលវេលា ។

**មាត្រា ៨** : បុគ្គលដែលចង់ចូលជាសមាជិករបស់ សអគក ត្រូវដាក់ពាក្យសុំចូលជាសមាជិក មកគណៈកម្មាធិការប្រតិបត្តិ ។

**មាត្រា ៩** : សមាជិកទាំងអស់ អាចមានសិទ្ធិទទួលនូវសមិទ្ធិផល ឬសេវាកម្មផ្សេងៗ ពីសហគមន៍ តាមលទ្ធភាពរបស់ សអគក ។

**មាត្រា ១០** : ការបញ្ចប់សមាជិកភាព ត្រូវអនុវត្តចំពោះសមាជិកណា ដែលមានលក្ខណៈ ដូចខាងក្រោមនេះ ÷

- បោះបង់ការងារដោយគ្មានមូលហេតុ រឺខកខានមិនបានបំពេញភារកិច្ចជាច្រើនលើក ។
- រំលោភលើលក្ខន្តិកៈ និង/ឬ បទបញ្ជាផ្ទៃក្នុងរបស់ សអគក ។

- ធ្វើឱ្យ សអគក ឈានទៅរកការបែកបាក់ ឬភាពអវិជ្ជមាន ។
- ប្រព្រឹត្តបទល្មើស ឬបទឧក្រិដ្ឋ ឬផ្សំគំនិតផ្សេងៗ ។

**មាត្រា ១១ :** ការបញ្ឈប់សមាជិក គឺត្រូវធ្វើឡើងដោយគណៈកម្មាធិការប្រតិបត្តិ តាមការបោះឆ្នោតដោយសម្លេងភាគច្រើន ២/៣ ។

**មាត្រា ១២ :** សមាជិកដែលសុំបញ្ឈប់សមាជិកភាពរបស់ខ្លួន ត្រូវដាក់ពាក្យសុំឈប់មកគណៈកម្មាធិការប្រតិបត្តិ ប៉ុន្តែសមាជិករូបនេះ អាចដាក់ពាក្យសុំចូលវិញបាន តាមការពិនិត្យរបស់គណៈកម្មាធិការប្រតិបត្តិ ។
ប៉ុន្តែករណីដូចមានចែងក្នុងមាត្រា ១០ នៃលក្ខន្តិកៈនេះ នឹងមិនត្រូវអនុញ្ញាតឱ្យដាក់ពាក្យជាថ្មី ដើម្បីសុំចូលជាសមាជិក សអគក វិញឡើយ ។

## ជំពូកទី ៤

## គណៈគ្រប់គ្រង

### ក. ប្រធានកិត្តិយស

**មាត្រា ១៣ :** ប្រធានកិត្តិយសរបស់ អសគក គឺជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងកាន់ដំណែង ។

### ខ. ក្រុមប្រឹក្សាភិបាល

**មាត្រា ១៤ :** សអគក មានក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាពដូចខាងក្រោម :

- តំណាងក្រសួងអប់រំ យុវជន និងកីឡា ០១ រូប
- តំណាងរាជបណ្ឌិតសភាកម្ពុជា ០១ រូប
- ម្ចាស់ជំនួយ ០១ រូប
- ឥស្សរជនជាតិ និងអន្តរជាតិ ០១ រូប
- តំណាងសង្គមស៊ីវិល ០១ រូប
- តំណាងសមាជិកស្ថាបនិករបស់ សអគក មួយរូប ដែលមានតួនាទីជាអ្នកទំនាក់ទំនង ។

**មាត្រា ១៥ :** ក្រុមប្រឹក្សាភិបាលរបស់ សអគក មានតួនាទីដូចតទៅ :

- ជួយទាក់ទងរកថវិកាបម្រើសហគមន៍ ។
- ផ្តល់យោបល់ ដើម្បីរកការរីកចម្រើនក្នុងសហគមន៍ ។
- ពិនិត្យសកម្មភាពរបស់សហគមន៍ ។

**មាត្រា ១៦ :** ក្រុមប្រឹក្សាភិបាល អាចត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំតាមការចាំបាច់ ដោយមានប្រធានគណៈកម្មាធិការប្រតិបត្តិជាអ្នកសម្របសម្រួល ។

### គ. គណៈកម្មាធិការនាយក

**មាត្រា ១៧ :** សអគក មានគណៈកម្មាធិការនាយកមួយ ដែលមានសមាសភាពដូចតទៅ :

- ប្រធានសហគមន៍ ០១ រូប
- តំណាងក្រុមប្រឹក្សាភិបាល ០៣ រូប

- តំណាងសមាជិកស្ថាបនិក ០៣ រូប
- តំណាងអ្នកស្រាវជ្រាវរបស់ សអគក ០២ រូប

សមាសភាពរបស់គណៈកម្មាធិការនាយកនេះ អាចមានការប្រែប្រួលតាមការចាំបាច់ ។

**មាត្រា ១៨ :** ប្រធានគណៈកម្មាធិការនាយក ត្រូវបានបោះឆ្នោតជ្រើសរើសចេញពីតំណាងសមាជិកស្ថាបនិក សម្រាប់អាណត្តិ ០៣ ឆ្នាំ។ ការបោះឆ្នោតត្រូវបានធ្វើឡើងដោយសម្លេងភាគច្រើន ២/៣។ ប្រធានសហគមន៍មិនអាចឈរឈ្មោះជាប្រធានគណៈកម្មាធិការនាយកបានទេ ។

**មាត្រា ១៩ :** តួនាទី ភារកិច្ចរបស់គណៈកម្មាធិការនាយក នឹងមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ សអគក ។

**ឃ. គណៈកម្មាធិការប្រតិបត្តិ**

**មាត្រា ២០ :** សអគក ដឹកនាំដោយគណៈកម្មាធិការប្រតិបត្តិមួយ ដែលមានសមាសភាពដូចតទៅ :

- ប្រធាន ០១ រូប
- អនុប្រធាន ០២ រូប
- អគ្គលេខាធិការ ០១ រូប
- ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ច ០១ រូប
- ប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ និងអាហារូបករណ៍ ០១ រូប
- ប្រធានការិយាល័យព័ត៌មាន បោះពុម្ពផ្សាយនិង បណ្ណាល័យនានាទូទាំងប្រទេស ០១ រូប
- ប្រធានការិយាល័យតំណាងសហគមន៍តាមគ្រឹះស្ថានសិក្សាទូទាំងប្រទេស ០១ រូប
- ប្រធានការិយាល័យមុខជំនាញឯកទេស និងបណ្ដុះបណ្ដាលបន្ត ០១ រូប
- ប្រធានការិយាល័យកម្មវិធីសិក្សា និងសៀវភៅ‹ បង្រៀន› សិក្សា ០១ រូប
- ប្រធានការិយាល័យគរុកោសល្យ និងវិធីសាស្ត្របង្រៀននិងប្រវត្តិនៃការរីកចំរើនគណិតវិទ្យា ០១ រូប

សមាសភាពគណៈកម្មាធិការប្រតិបត្តិនេះ អាចមានការប្រែប្រួលតាមការចាំបាច់ ។

**មាត្រា ២១ :** ប្រធាន សអគក ត្រូវបានគណៈកម្មាធិការនាយក បោះឆ្នោតជ្រើសរើសសម្រាប់អាណត្តិ ០៣ ឆ្នាំម្ដង ហើយអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសទៀតបាន តែមិនឱ្យលើសពី ០២ អាណត្តិឡើយ ។
ដែលអាចនឹងឈរឈ្មោះជាប្រធានបាន លុះត្រាតែបេក្ខជននោះ មានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតឡើងទៅ ។
ការបោះឆ្នោតត្រូវធ្វើជាសម្ងាត់ ហើយត្រូវមានសម្លេងភាគច្រើន ២/៣ ។

**មាត្រា ២២ :** អនុប្រធានទាំងពីររបស់ សអគក ត្រូវបានតែងតាំងដោយប្រធាន ។ ដែលអាចនឹងត្រូវបានតែងតាំងធ្វើជាអនុប្រធាន សអគក បាន លុះត្រាតែបុគ្គលនោះមានសញ្ញាប័ត្រចាប់ពីថ្នាក់អនុបណ្ឌិតឡើងទៅ ។

**មាត្រា ២៣ :** ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ច ការិយាល័យទំនាក់ទំនងអន្តរជាតិ និងអាហារូបករណ៍ ការិយាល័យពត៌មាន បោះពុម្ពផ្សាយ និងបណ្ណាល័យ ការិយាល័យតំណាងសហគមន៍ តាមគ្រឹះស្ថានសិក្សានានាទូទាំងប្រទេស ការិយាល័យមុខជំនាញឯកទេស និងបណ្ដុះបណ្ដាលបន្ត ការិយាល័យកម្មវិធីសិក្សា និងសៀវភៅសិក្សា-បង្រៀន ការិយាល័យគរុកោសល្យ វិធីសាស្ត្របង្រៀន និងប្រវត្តិនៃការរីកចំរើន

គណិតវិទ្យា និងប្រធានការិយាល័យផ្សេងៗ ទៀតតាមការចាំបាច់ ត្រូវបានតែងតាំងដោយប្រធាន តាមការស្នើសុំពីអនុប្រធានទាំងពីររបស់សមាគមន៍។ ការដកហូត ឬផ្លាស់ប្តូរមុខតំណែងរបស់ប្រធានការិយាល័យណាមួយត្រូវបានធ្វើឡើង ដោយការបោះឆ្នោតរបស់គណៈកម្មាធិការប្រតិបត្តិ ដោយយកសម្លេងភាគច្រើន ២/៣ ក្នុងករណី ដែលប្រធានការិយាល័យរូបនោះ បានប្រព្រឹត្តដូចមានចែងក្នុងមាត្រា ១០ នៃលក្ខន្តិកៈនេះ។

**មាត្រា ២៤ :** សមាជិកគណៈកម្មាធិការប្រតិបត្តិណា ដែលមិនបានមកប្រជុំ ៥ ដងជាប់ៗគ្នា ដោយគ្មានមូលហេតុត្រឹមត្រូវ ទុកដូចជាសុំលាលែង។

**មាត្រា ២៥ :** បើសមាជិកគណៈកម្មាធិការប្រតិបត្តិណា មិនបានបំពេញមុខងាររបស់ខ្លួនដូចបានកំណត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងឱ្យបានត្រឹមត្រូវទេ គណៈកម្មាធិការប្រតិបត្តិត្រូវហូតងារសមាជិកនោះចេញ។

**មាត្រា ២៦ :** កាលណាប្រធានគណៈកម្មាធិការប្រតិបត្តិ ឬ សមាជិកភាគច្រើននៃគណៈកម្មាធិការប្រតិបត្តិ អញ្ជើញឱ្យមកប្រជុំ នោះគណៈកម្មាធិការប្រតិបត្តិ ត្រូវតែប្រជុំយ៉ាងតិច ១ ដង ក្នុងមួយខែ ឬរាល់តែដងណា ដែលត្រូវការប្រជុំប្រយោជន៍ឱ្យសមាគមន៍បានជឿនលឿនទៅមុខ។

**មាត្រា ២៧ :** តួនាទី ភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិ នឹងមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ សរគក។

## ជំពូកទី ៥

## ចំណូល និងចំណាយ

**មាត្រា ២៨ :** ចំណូលរបស់សមាគមន៍បានមកពី ÷

- ប្រាក់ឧបត្ថម្ភរបស់សមាជិក សរគក។
- ជំនួយផ្សេងៗពីរាជរដ្ឋាភិបាល ពីសប្បុរសជន និងអង្គការនានា ទាំងក្នុង និងក្រៅប្រទេស។
- ចំណូលបានមកពីសកម្មភាពផ្សេងៗ ដែលចាត់តាំងធ្វើជាផលប្រយោជន៍ដល់សមាគមន៍។

**មាត្រា ២៩ :** ចំណាយរបស់សមាគមន៍ចែកជាពីរប្រភេទ ÷

- ចំណាយសម្រាប់ការងាររដ្ឋបាល។
- ចំណាយសម្រាប់ការងារស្រាវជ្រាវការងារបណ្តុះបណ្តាលបន្តនិងបោះពុម្ពផ្សាយ។

## ជំពូកទី ៦

## មហាសន្និបាត និងការប្រជុំនានា

**មាត្រា ៣០ :** មហាសន្និបាតរួមមាន មហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ ហើយត្រូវបានរៀបចំដោយគណៈកម្មាធិការនាយក។

**មាត្រា ៣១ :** មហាសន្និបាតសាមញ្ញ ត្រូវប្រព្រឹត្តឡើងក្នុង ៣ ឆ្នាំម្តង ដោយមានការចូលរួមពីសមាជិកទាំងអស់ របស់សមាគមន៍។ មហាសន្និបាតសាមញ្ញអាចប្រព្រឹត្តទៅ តាមការអញ្ជើញរបស់គណៈកម្មការនាយក។ នីតិវិធីរបៀបវារៈ ទីកន្លែង និងពេលវេលា ត្រូវបានស្នើឡើងដោយគណៈកម្មការនាយក។ ការកត់ត្រាកំណត់ហេតុ នៃអង្គមហាសន្និបាត ជាភារកិច្ចរបស់ការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ច។

**មាត្រា ៣២ :** មហាសន្និបាតសាមញ្ញធ្វើឡើង ដើម្បីស្តាប់សេចក្តីរាយការណ៍ប្រចាំអាណត្តិរបស់គណៈកម្មាធិការប្រតិបត្តិ សអគក អំពីបញ្ហាទាំងឡាយ ដែលទាក់ទងនឹង សអគក និងសេចក្តីរាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពការងារប្រចាំអាណត្តិ ។

**មាត្រា ៣៣ :** គណៈកម្មាធិការនាយក ត្រូវអញ្ជើញសមាជិក សអគក ឱ្យចូលរួមមហាសន្និបាតក្នុងរយៈពេលយ៉ាងតិច ២០ ថ្ងៃ មុនកាលបរិច្ឆេទនៃការប្រជុំ ។

**មាត្រា ៣៤ :** មហាសន្និបាតវិសាមញ្ញ ធ្វើឡើងក្នុងករណីចាំបាច់ ដែលដំណើរការក្នុងចន្លោះនៃមហាសន្និបាតសាមញ្ញ តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការនាយក តាមសំណូមពរ ២/៣ នៃសមាជិកគណៈកម្មា-ធិការនាយក ឬដោយមានពាក្យស្នើសុំមានចុះហត្ថលេខាចំនួន ១/៤ នៃសមាជិកសហគមន៍ ។ នីតិវិធី របៀបវារៈ ទីកន្លែង និងពេលវេលា ត្រូវបានស្នើឡើងដោយប្រធានគណៈកម្មាធិការនាយក ។ ការកត់ត្រា កំណត់ហេតុនៃអង្គមហាសន្និបាត ជាភារកិច្ចរបស់ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ។

**មាត្រា ៣៥ :** មហាសន្និបាតវិសាមញ្ញធ្វើឡើង ដើម្បីដោះស្រាយនូវសំណូមពរចាំបាច់ផ្សេងៗ ដែលស្នើឡើងដោយ គណៈកម្មាធិការនាយក ឬគណៈកម្មាធិការប្រតិបត្តិ ។

**មាត្រា ៣៦ :** មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ នឹងពិភាក្សាទៅទុកជាជាបានការ លុះណាតែសមាជិកដែលបានមក ប្រជុំមានចំនួនយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកទាំងអស់របស់សហគមន៍ដែលត្រូវបានអញ្ជើញ ។

**មាត្រា ៣៧ :** កាលបើមហាសន្និបាតមិនអាចពិភាក្សាបាន ដោយខ្វះសមាជិកគ្រប់ចំនួន (កូរ៉ុម) នោះត្រូវធ្វើសេចក្តី អញ្ជើញជាថ្មី ក្នុងរយៈពេល ៣០ ថ្ងៃក្រោយមក ។

មហាសន្និបាត ដែលប្រជុំដោយសេចក្តីអញ្ជើញលើកទី ២ អាចពិភាក្សាទៅទុកថា ជាបានការ តាមតែ សមាជិកអញ្ជើញមកប្រជុំចំនួនប៉ុន្មានក៏ដោយ ។

**មាត្រា ៣៨ :** សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកតាមមតិភាគច្រើនហាសិបភាគរយបូកមួយ (៥០% + ១) ។ បើសម្លេងស្មើគ្នានោះ ត្រូវបោះឆ្នោតជាថ្មី ។ ប៉ុន្តែបើសម្លេងឆ្នោតនៅតែស្មើគ្នាទៀត សម្លេងប្រធានត្រូវ មានឧត្តមានុភាព ។

**មាត្រា ៣៩ :** គណៈកម្មាធិការប្រតិបត្តិត្រូវជួបប្រជុំគ្នាយ៉ាងតិច ០១ ដងក្នុង ០១ ខែ តាមការអញ្ជើញរបស់ប្រធាន សហគមន៍ ដោយជូនភ្ជាប់នូវរបៀបវារៈ ទីកន្លែង និងពេលវេលាមកជាមួយផង ។ នីតិវិធីការកត់ត្រា កំណត់ហេតុអង្គប្រជុំ ជាភារកិច្ចរបស់ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ច ។

**មាត្រា ៤០ :** អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិធ្វើឡើង ដើម្បី :

- ពិភាក្សា និងសម្រេចលើការអនុវត្តន៍របស់ខ្លួនកន្លងមក ។
- ពិភាក្សា និងសម្រេចលើការចុះហត្ថលេខាលើកិច្ចសន្យានានា ។
- ពិភាក្សា និងសម្រេចដកហូតមុខតំណែងរបស់សមាជិកគណៈកម្មាធិការប្រតិបត្តិរូបណាមួយ ។
- ពិភាក្សា និងសម្រេចលើការអនុញ្ញាតឱ្យចូល ឬដកហូតសមាជិកភាព នៃសមាជិកសហគមន៍ ។
- ពិភាក្សារកដំណោះស្រាយ រកមូលនិធិ និងការដោះស្រាយថវិកាសម្រាប់គម្រោងការងារប្រចាំឆ្នាំ ។

- ពិនិត្យ និងសម្រេចលើរបាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើឡើងដោយប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ច និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត ។
- រៀបចំរបាយការណ៍ស្តីពីសកម្មភាព និងស្ថានភាពហិរញ្ញវត្ថុ តារាងតុល្យការ ជូនអង្គមហាសន្និបាត ។

**មាត្រា ៤១ :** ការប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ សអតក ដែលដំណើរការបាន លុះណាតែសមាជិកដែលបានមកប្រជុំ មានចំនួនយ៉ាងតិចពីរភាគបី (២/៣) នៃសមាជិកទាំងអស់ ។

**មាត្រា ៤២ :** រាល់សេចក្តីសម្រេច នៃអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិរបស់សមាគមន៍ មានតម្លៃគតិយុត្តិបាន លុះត្រាមានការអនុម័តដោយសម្លេង ២/៣ នៃសមាជិកគណៈកម្មាធិការប្រតិបត្តិ ដែលបានចូលរួមប្រជុំ ។

## ជំពូកទី ៧
## វិសោធនកម្មលក្ខន្តិកៈ និងការរំលាយសមាគមន៍

**មាត្រា ៤៣ :** ការធ្វើវិសោធនកម្មលក្ខន្តិកៈសមាគមន៍ ត្រូវមានសំណូមពរ ១/៣ នៃសមាជិកគណៈកម្មាធិការនាយក រួចដាក់ឆ្លងគណៈកម្មាធិការនាយកសម្រេច ដោយមានការបោះឆ្នោតអនុម័តសម្លេងភាគច្រើន ២/៣ ។

**មាត្រា ៤៤ :** រាល់មាត្រាទាំងឡាយនៃលក្ខន្តិកៈនេះ ដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែធ្វើវិសោធនកម្មជាចាំបាច់ ។

**មាត្រា ៤៥ :** មានតែគណៈកម្មាធិការនាយកទេ ដែលមានសិទ្ធិរំលាយសមាគមន៍បាន តាមការបោះឆ្នោតសម្រេចយល់ព្រមដោយសម្លេងភាគច្រើន ២/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងអស់ ។

**មាត្រា ៤៦ :** ក្រោយពេលត្រូវប្រកាសរំលាយ រាល់ទ្រព្យសម្បត្តិទាំងអស់របស់សមាគមន៍ ដែលនៅសល់ក្រោយពីការជម្រះបំណុលស្របច្បាប់ គឺត្រូវផ្ទេរប្រគល់ជូនជាទ្រព្យសម្បត្តិរដ្ឋទាំងស្រុង ឬផ្តល់ជូនអង្គការ ឬសមាគមន៍ដែលមានគោលបំណងដូចគ្នា ។ ចំពោះទ្រព្យសម្បត្តិឯកជន ត្រូវប្រគល់ជូនម្ចាស់ដើមវិញ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៤៧ :** រាល់ដំណើរការរបស់សមាគមន៍ ត្រូវអនុវត្តតាមលក្ខន្តិកៈនេះ ជាដាច់ខាត ។ បទបញ្ញត្តិផ្សេងៗ ដែលផ្ទុយនឹងលក្ខន្តិកៈនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤៨ :** លក្ខន្តិកៈនេះ ត្រូវប្រកាសឱ្យប្រើប្រាស់ជាទូទៅសម្រាប់ សអតក ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ខែ មករា ឆ្នាំ ២០០៥

**ប្រធានសមាគមន៍**

**បណ្ឌិត ចាន់ ពន**